# ជីវិត Life

"ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យមាន
ជីវិតយ៉ាងបរិបូរណ៍"។
(យ៉ូហាន:១០,១០)

សកម្មភាពព្រះសហគមន៍ភូមិភាគភ្នំពេញ

លេខ១១ សម្រាប់ ថ្ងៃទី០១-៣១ ខែធ្នូ ឆ្នាំ២០១២








**អេម៉ាន្នូអែល**

សំឡេងព្រះសហគមន៍កាតូលិក FM 102.5 Mhz

ម៉ោង ២:០០ - ៣:០០ រាល់ថ្ងៃសុក្រ

**ខ្ញុំត្រូវការអ្នក (I NEED YOU)**

រាល់ថ្ងៃអង្គារ FM 99.5 Mhz

ម៉ោង ១០:០០ - ១១:០០ ព្រឹក

# បងប្អូនជាទីស្រឡាញ់



ថ្ងៃនេះ យើងប្រារព្ធថ្ងៃបុណ្យរំលឹកសម្តេច ប៉ាប យ៉ូហានប៉ូលទី២ ប្រកបដោយសុភមង្គលនៅក្នុងឱកាសនេះ ខ្ញុំក៏បានអធិដ្ឋានរួមជាមួយបងប្អូនទាំងអស់គ្នាពីទីក្រុងរ៉ូមផងដែរ។

មហាសន្និបាតរបស់លោកអភិបាល ជាបទពិសោធន៍ដ៏ល្អពីព្រោះយើងមានឱកាសរស់នៅជាមួយបងប្អូនអភិបាល និងការពិភាក្សាទល់មុខគ្នា។

ខ្ញុំមានការយល់ដឹងកាន់តែច្បាស់ អំពីបទពិសោធន៍របស់ព្រះសហគមន៍នៅមជ្ឈឹមបូព៌ានតាមរយៈ សក្ខីភាពឈឺចាប់ខ្លោចផ្សារបស់លោកអភិបាលតំបន់នោះ។ ប្រធានបទនៃការប្រកាលដំណឹងល្អថ្មី មានភាពទូលំទូលាយដ៏ធំធេង តែក៏ជាឱកាសមួយក្នុងការប្រែចិត្តយើងជាថ្មីម្តងទៀត ឲ្យធ្វើជាសាក្សីដោយមានការចាប់អារម្មណ៍ជាខ្លាំងអំពីជំនឿរបស់យើង និងអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះគ្រីស្ត។

សម្តេចប៉ាប បានចូលរួមនៅក្នុងកិច្ចប្រជុំភាគច្រើនរបស់យើង និងព្រះជាម្ចាស់បានសព្វព្រះហឫទ័យឲ្យខ្ញុំថ្លែងនៅក្នុងកិច្ចប្រជុំជាទូទៅ នៅពេលមានវត្តមានរបស់សម្តេចប៉ាប ចំថ្ងៃដែល ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាយាងចូលទីវង្គត។ ក្នុងចន្លោះពេលនោះដែរ លោកអភិបាលតំណាងព្រះសហគមន៍ទូទាំងសកលលោកបានរួបរួមជាមួយប្រទេសកម្ពុជានិងប្រទេសឡាវ។

ពិតណាស់នៅព្រះរាជាណាចក្រកម្ពុជាយើងមានឱកាសឆ្លងកាត់បទពិសោធន៍របស់សហគមន៍គ្រីស្តបរិស័ទដើមដំបូង។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា ឆ្នាំនៃជំនឿដែលយើងបានបើកប្រារព្ធជាមួយគ្នា នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១២ នឹងក្លាយជាឆ្នាំពោរពេញដោយភ្លើងនៃព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់ព្រះសហគមន៍របស់យើង។

សូមព្រះជាម្ចាស់ប្រទាន ព្រះពរឲ្យអស់បងប្អូន និងរក្សាបងប្អូននៅក្នុងសេចក្តីសុខសាន្តរបស់ព្រះអង្គ។

ពីលោកអភិបាលអូលីវីយេ
ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ

## Dear Brother Priests,

Today, we celebrate the Feast of Blessed John Paul II, and my prayers from Rome are joined with all of yours.

The Synod of Bishops is a beautiful experience of collegiality and encounters. Now I have a better understanding of the experiences of the church in the Middle East through the poignant testimony of their pastors.

The theme of the New Evangelization is vast, but it is an opportunity to convert us again to be enthusiasticwitnesses of our faith and of the charity of Christ.

The Holy Father participates in most of our meetings and Providence willed that I speak in the general meeting in the presence of the Holy Father on the day of the death of King Sihanouk. For five minutes the Church of the whole World was united with Cambodia and Loas.

The opening of the Year of Faith, with the celebration of the 50th anniversary of Vatican II, was a wonderful time. Bishop Ramousse joined me on this special day with 11 other council fathers!

Then yesterday we attended the canonization of 7 new saints, models for evangelists!

I am happy to meet many superiors of religious congregations and those responsible for groups working in Cambodia.All of them greet you and assure you of their prayers.

In my brief speech, I talked of my wishes forthe Church as a sign of the Charity of Christ, simple and welcoming, prayerful and joyful.

Now in Cambodia, we have the opportunity to relive the experience of the early Christian communities. This Year of Faith, that we have just opened, can be a year of fire for our Church.

God bless you and keep you in his peace,

Bishop Olivier.
Your bishop

# ដំណើរចាកចេញពីប្រទេសកម្ពុជា ទៅកាន់បេសកកម្មថ្មីលើទឹកដីថ្មី នៅប្រទេសវៀតណាម របស់បងស្រី ហ្វីល





បងប្អូនគ្រីស្តបរិស័ទទូទាំងមណ្ឌលសកម្មភាពក្រុងព្រះសីហនុស្គាល់ បងស្រី ហ្វីល ជាបងស្រីនៃក្រុម ដូមីនិក បានមកបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា ជាង ប្រាំពីរឆ្នាំហើយ។

បងស្រីបានស្ម័គ្រចិត្តបម្រើព្រះសហគមន៍ នៅមណ្ឌលសកម្មភាពព្រះសីហនុ។

កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១២ នៅព្រះសហគមន៍កាតូលិកកំពង់សោមបានប្រារព្ធពិធីអរគុណព្រះជាម្ចាស់ចំពោះវត្តមានបងស្រីដែលបានលះបង់កំលាំងកាយកំលាំងចិត្តដើម្បីបំរើដល់ព្រះសហគមន៍យើង។ ក្នុងរយៈពេល ជាង៧ឆ្នាំ បងស្រីបានខិតខំបំពេញបេសកកម្មអស់ពីកម្លាំងកាយ ចិត្តដោយ។

មុនពេលចេញទៅបំពេញបេសកកម្មនៅប្រទេសវៀតណាម បងស្រីបានមានប្រសាសន៍ថា បទពិសោធន៍នៃការបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជាគឺជាអំណោយទានដ៏វិសេសវិសាលដែលព្រះជាម្ចាស់បានប្រទានឲ្យ។ បងស្រីបន្ថែមថា បងស្រីពិតជាមិនអាចបំភ្លេច នូវសេចក្តីស្រលាញ់ដែល គ្រីស្តបរិស័ទ និងព្រះសហគមន៍បានផ្តល់ឲ្យក្នុងរយៈពេលដែលបងស្រីនៅក្នុងប្រទេសកម្ពុជានោះទេ។ "ព្រះជាម្ចាស់បានរៀបចំគំរោងការណ៍យ៉ាងច្បាស់សម្រាប់ជីវិតរបស់ខ្ញុំ ទោះបីខ្ញុំត្រូវឃ្លាតចាកឆ្ងាយពីមនុស្សជាទីស្រលាញ់ក៏ដោយ តែខ្ញុំទទួលបាននូវភាពកក់ក្តៅពីព្រះអង្គជារៀងរហូត"។

## Sister Fil Ended Her Mission in Cambodia

Sister Fil, a member of the Dominican congregation who worked in Cambodia more than seven years is now serving in her new mission in Vietnam.

On October 7 the pastoral center was pleased to celebrate with Sister Fila mass ofthanksgiving for her great contribution to the growth of the church. SisterFilspoke of her memories of Cambodia as a warm country and of God's gift that placed her here. She was involved in different activities with the poor in almost all the communities of the Sihanouk pastoral center. In all those experiences, SisterFil found the grace and love of God and felt that she was part of God's plan.

"I am sad to leave all the beloved people whom I have met during my mission, but what I need to do now is to do God's will. That, I believe, will give me the happiness of God," said Sr. Fil.

*Ms . Chanthy*

# លោកអភិបាលសុខកុមារអូលីវីយេ ចូលរួមបុណ្យកឋិនទានវត្តអង្គមន្ត្រី





លោកអភិបាលអូលីវីយេ បានចូលរួមពិធីបុណ្យកឋិន ទានតាមប្រពៃណីពុទ្ធបរិស័ទ នៅវត្តអង្គមន្ត្រីស្ថិតក្នុងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវនាថ្ងៃទី ០២ ខែវិច្ឆិកា ពេលថ្មីៗនេះ ។

លោកអភិបាលបានថ្លែងក្នុងពិធីនោះថា លោកមានអំណរសប្បាយ ប្រកបដោយភាពកក់ក្តៅដែលទទួលបាននូវការទទួលស្វាគមន៍ពីសំណាក់ លោកយាយ  លោកតា បងប្អូនប្រុសស្រីទាំងអស់។លោកបានបន្តថា ទោះបីយើងកាន់សាសនាផ្សេងពីគ្នាក្តី ប៉ុន្តែអ្វីដែលសំខាន់និងមានតម្លៃនោះគឺយើងមានកិច្ចសហប្រតិបត្តិការល្អរវាងគ្នានិងគ្នា ដោយចេះចាប់ដៃគ្នា មានទំនាក់ទំនងល្អ ដើរផ្លូវរួមគ្នា ដើម្បីបង្ហាញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធ បន្តចាប់ដៃគ្នាដើម្បីយកចិត្តទុកដាក់ដល់អ្នកក្រីក្រ និងជនគ្មានទីពឹង ស្វែងរកភាពសុខសាន្ត សុភមង្គល សេចក្តីសង្ឃឹម ព្រមទាំងកសាងពិភពលោកពោរពេញដោយសន្តិភាព និងភាពសុខដុមរមនា ។

លោកតា ណុប គឿង ប្រធានគណៈកម្មការអាចារ្យវត្ត មានប្រសាសន៍ថា ព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្ត នៅទីនេះក៏មានសេចក្តីសោមនស្សរីករាយដែល ព្រះសហគមន៍កាតូលិកមានបំណង សាមគ្គីភាព មិត្តភាព និងមានទំនាក់ទំនងកាន់តែជិតស្និទ្ធថែមទៀត។នៅក្នុងឱកាសនេះផងដែរលោកអភិបាលអូលីវីយេ បានឧបត្ថម្ភបច្ច័យចំនួន ៣០០០ ដុល្លារអាមេរិកទៀតក្នុងការរួមចំណែកកសាងសាលាឆាន់ថ្មីក្នុងទីអារាមនេះ ។

## Bishop Olivier attends Bon Kathen in Takeo

Bishop Olivier joined the Bon Kathen, a Buddhist festival in Cambodia, at Wat AngMontry in Takeo on November 2.

He had a warm welcome from the Buddhists and the monks . Bishop Olivier was very pleased to join the program. He said there is great significance and value when we come together with different perspectives on religion and create a concrete peace in which all people can live in truth and dignity. “Together we build the world with peace and harmony,” said Bishop Olivier.

Mr. Nob Poeung, the chief of the committee of Wat AngMontry, said all the people joyfully welcome such a peaceful collaboration with the Catholics. He added that we have to work harder to create peace and truth in the world. “I find a lot of qualities in the real practices of Christians,” said Mr. Poeung.

*យុន សំអាត*

# ពិធីសម្ពោធកីឡាដ្ឋាន និង បើកវគ្គសិក្សានៅវិទ្យាស្ថានសន្តប៉ូល

កាលពីថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១២ នៅវិទ្យាស្ថានសន្តប៉ូលបានធ្វើការបើកឆ្នាំសិក្សាថ្មី ២០១២-២០១៣ និងសម្ពោធកីឡាដ្ឋាន រួមជាមួយការប្រគល់សញ្ញាប័ត្រថ្នាក់បរិញ្ញាបត្ររងជំនាន់ទី២ និងទី៣ចំនួន៦៨នាក់ និងថ្នាក់សិក្សាមូលដ្ឋាន ១៦០នាក់ក្រោមអធិបតីភាពរបស់ឯកឧត្តម អ៊ឹម សិទ្ធី ជារដ្ឋមន្ត្រីនៃក្រសួងអប់រំ យុវជននិងកីឡា ។

ក្នុងឱកាសដ៏ឱឡារិកនេះ លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ឲ្យដឹងថា វិទ្យាស្ថានសន្តប៉ូល ក៏មានគោលដៅដើម្បីកសាងអនាគតនិស្សិត ដោយផ្តល់ឱកាសឲ្យពួកគេអាចរកឃើញនូវសេចក្តីពិត ក្នុងជីវិតនិងក្នុងសង្គមជាតិដែលគេរស់នៅ។ លោក អភិបាលបានឲ្យដឹងថា វិទ្យាស្ថានសន្តប៉ូលត្រូវបានគេទទួលស្គាល់ជាផ្លូវការជាសមាជិកនៃសាកលវិទ្យាល័យនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍កាលពីឆ្នាំ ២០០៨មកម្ល៉េះ។ លោកបន្តថាវិទ្យាស្ថាននឹងមានគម្រោងពង្រីក មុខវិជ្ជាកិច្ចការសង្គម និងគ្រូពេទ្យមធ្យម នៅក្នុងឆ្នាំ២០១៤ខាងមុខ។

ឯកឧត្តម អ៊ឹម សទ្ធីបានមានប្រសាសន៍ឲ្យដឹងថាវិទ្យាស្ថានសន្ត ប៉ូល គឺជាថ្នាលបណ្តុះធនធានមនុស្ស មួយដែលបានខិតខំចូលរួមចំណែកក្នុងការអភិវឌ្ឍន៍កម្ពុជា។ លោកក៏បានលើកទឹកចិត្តឲ្យមានការអនុវត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់និស្សិតក្នុងមូលដ្ឋានរបស់ខ្លួន។

## H.E Im Sithy presides at the inauguration of New Academic Year and Sports Ground at St. Paul Institute

The new ecademic year and a new sports ground were offically inaugurated by H. E. Im Sithy, theMinister of Education and Sports, on November 8 at Takeo province.

On that occasion, H. E. Im Sithy delivered certificates to 68 second and third Sub Bachelor degree candidates and to another 160 foundation year candidates.

Bishop Olivier, the founder and Director of the school, said St. Paul has been purposely established in order to create paths forthe students to find truth in their lives and society, so that they can live in a harmonious world. He added that St. Paul now is officially recognized by the Catholic Universities in South East Asia. “We are also going to add two other majors,social work and nursing,” said Bishop Olivier.

H.E Im Sithy said St. Paul is a part of human resource development in Cambodia. “We work hard together to respond to the needs of our youth,” he added.





# សម្ពោធផ្លូវបេតុងជាជំនួយរបស់ក្រុមព្រះបេះដូងព្រះយេស៊ូនៅចំប៉ា

ផ្លូវបេតុងមួយខ្សែប្រវែងប្រហែល ១០០ ម៉ែត្រត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ក្រោមអធិបតីភាពរបស់លោកអភិបាលអូលីវីយេ កាលពីថ្ងៃទី ២ខែវិច្ឆិកាកន្លងទៅនេះ។

លោកបូជាចារ្យវិរៈជ័យជាអ្នកទទួលខុសត្រូវមណ្ឌលសកម្មភាពទន្លេមេគង្គ បានឲ្យដឹងថា ផ្លូវបេតុងមួយខ្សែខ្លីនេះដែលមានប្រវែង៩៣ម៉ែត្រ និងទទឹង ៤ម៉ែត្រ គឺជាជំនួយសប្បុរសជននៃក្រុមព្រះបេះដូងព្រះយេស៊ូនៅប្រទេសវៀតណាម និងការចូលរួមពីសំណាក់បងប្អូនគ្រីស្តបរិស័ទនៅក្នុងព្រះសហគមន៍ចំប៉ាដែរ។ លោកបានឲ្យដឹងទៀតថា ថវិកាមួយចំនួនទៀតពួកគាត់បានយកទៅប្រើដើម្បីធ្វើតខ្លោងទ្វា និងជួសជុលអាគាព្រះវិហារខាងក្នុងដើម្បីឲ្យមានសោភណ្ឌភាពស្អាត។

លោកអភិបាលអូលីវីក៏ឆ្លៀតឱកាសដើម្បីអរគុណ និងអភិបូជាមួយក្រុមបេះដូងសាវ័កដែលមកពីប្រទេសវៀតណាម និងពីបណ្តាព្រះសហគមន៍ផ្សេងៗក្នុងប្រទេសកម្ពុជា។ លោកបានបន្តទៀតថា ក្រុមព្រះបេះដូងព្រះយេស៊ូនឹងធ្វើជាពន្លឺមួយដែលជួយអ្នកដទៃឲ្យស្គាល់ពីព្រះយេស៊ូ ព្រោះក្រុមនេះសុខចិត្តបន្តបេសកម្មរបស់ក្រុមសាវ័កនៅសម័យបច្ចុប្បន្ននេះ។

លោក វ៉ាង ជាគ្រីស្តបរិស័ទ និងជាសមាជិកនៃក្រុមព្រះបេះដូងព្រះយេស៊ូមានប្រសាសន៍ថា ព្រះសហគមន៍ត្រូវការគ្រីស្តបរិស័ទដើម្បីកសាង និងរក្សាជំនឿឲ្យបានគង់វង្សជារៀងរហូត។ លោកបន្ថែមថា គំរូរបស់ក្រុមព្រះបេះដូងព្រះយេស៊ូជួយឲ្យយើងភ្ជាប់ជីវិតរបស់យើងយ៉ាងជិតស្និទ្ធទៅនឹងព្រះជាម្ចាស់ ដោយសុខចិត្តបម្រើព្រះសហគន៍ក្នុងរូបភាពណាមួយ។ លោកបន្តថា ពេលណាយើងមានចិត្តសហការធ្វើការជាមួយក្រុមនានាក្នុងព្រះសហគមន៍បានល្អ នោះការរីកចំរើនដែលយើងនឹងទទួលបានក៏ធំដែរ។

## The Sacred Heart of Jesus Movement Funds A road for Champa community

A road 93 meters long and 4 meters wide was built by the Sacred Heart of Jesus Movement and was inaugurated by Bishop Olivier on November 2.

Fr. Wirachai, the priest in charge of the Tonle Mekong pastoral center based at Champa, said that theroad was partly funded by the Sacred Heart of Jesus group  and partly by the people in the village.

Bishop Olivier gave thanks to the Sacred Heart of Jesus Movement for their good work for the growth of the church. The Bishop also pointed out that they are to be a light that can lead others to know Jesus as they continue the mission of the early disciples.

Mr. Vang, a member of Sacred Heart of Jesus, said that the church needs different kinds of people who have variety of talents to evangelize and protect the faith.





# ផ្ទះប្រជាជននៅចំប៉ាត្រូវខូចខាតយ៉ាងដំណំដោយខ្យល់ព្យុះ



ផ្ទះ ៤ខ្នងត្រូវបានខូតខាតទាំងស្រុង ២៦ខ្នង ទៀតត្រូវបានដាច់ដំបូល និងទូកមួយចំនួនត្រូវបានលិចលង់ បន្ទាប់ពីព្យុះដ៏កំណាចមួយបានបោកបក់មកលើ ភូមិចំប៉ាកាលពីវេលាម៉ោង ៤កន្លះនាថ្ងៃទី ១១ខែវិច្ឆិកាកន្លងទៅនេះ។

កញ្ញា លីលីជាអ្នកបានឃើញព្រឹត្តការណ៍នេះផ្ទាល់នឹងភ្នែក បានរៀបរាប់ថាព្យុះដ៏កំណាចកម្រមួយនេះ បានកើតឡើងនៅវេលាម៉ោង ៤កន្លះល្ងាច ដោយលាយឡំជាមួយនឹងទឹកភ្លៀងដោគជាំ ដែលបានទិសដៅពីទិសខាងត្បូងទៅ ទិសខាងជើង ហើយវាបោកបក់ក្នុងរយៈពេលប្រហែលជា ១៥នាទី ចន្លោះពីម៉ោង៤កន្លះ ទៅម៉ោង៤:៤៥នាទីល្ងាច។ កញ្ញា បានឲ្យដឹងថា ផ្ទះប្រជាពលរដ្ឋចំនួន ៤ខ្នងត្រូវបានរលំបាក់យ៉ាងដំណំ តែសំណាងល្អគ្មានគ្រោះថ្នាក់ដល់មនុស្សណាម្នាក់ឡើង។ កញ្ញា បានបន្ថែមថា ផ្ទះជាច្រើនខ្នងទៀតត្រូវបានប៉ើងដំបូល និងទូកមួយចំនួនទៀត បានលិចលង់ ដោយបាត់បង់និងខូចខាតសំភារៈជាច្រើន។

ព្យុះនេះបានធ្វើឲ្យប្រជាជនក្រីក្រមានការលំបាកជាខ្លាំងក្នុងការចំណាយប្រាក់កាសដើម្បី ជួសជុល និងកសាងផ្ទះឡើងវិញ។

## Houses are affected by small Storm in Champa community

Four houses were totally destroyed, another 26 had their roofs torn off, and several boats were sunk by a storm which happened around 4:30 PM on November 11 in theChampa community.

Ms. Lyly reported that the small storm appeared on Monday at about 4:30 with strong winds and heavy rain. She said the storm lasted about 15 minutes, butfortunately, no one was injured.

***Ms. Lyly***

# គណកម្មការសង្គហព្រះសហគមន៍សន្តយ៉ូសែបផ្សារតូចផ្តល់អំណោយដល់គ្រួសារក្រីក្រក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ

គ្រួសារចំនួន៥០គ្រួសារបានទទួលអំណោយពីព្រះសហគមន៍សន្តយ៉ូសែបផ្សារតូចកាលពីថ្ងៃទីខែកញ្ញាកន្លងទៅនេះ។ លោក ថៃ បញ្ញាជាប្រធានគណកម្មការសង្គហព្រះសហគមន៍សន្តយ៉ូសែបបានមានប្រសាសន៍ថា ព្រះសហគមន៍បានរៀបចំកម្មវិធីនេះឡើង២ដងក្នុងមួយឆ្នាំ ដោយចែកអំណោយដល់អ្នកក្រីក្រមួយចំនួនក្នុងឱកាសបុណ្យចូលឆ្នាំថ្មី និងមួយដងទៀតនៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ។ លោកបានបន្តទៀតថា ចំនួនគ្រួសារក្រីក្រដែលត្រូវផ្តល់អំណោយគឺអាស្រ័យលើជំនួយដែលព្រះសហគមន៍ទទួលបានពីសប្បុរសជន និងគ្រីស្តបរិស័ទ។ លោកក៏បានឲ្យដឹងទៀតថា គ្រួសារក្រីក្រទាំងនោះគឺភាគច្រើនជាអ្នកចំណាកស្រុក និងអ្នកដែលរស់នៅតាមទន្លេដែលគ្មានមុខរបរជាក់លាក់។ ក្រៅពីផ្តល់ជំនួយជាសម្ភារៈដល់គ្រួសារ ព្រះសហគមន៍ក៏បានផ្តល់ជាថវិកាអាហារូបករណ៍ដល់សិស្សនិស្សិតដែលកំពុងរៀន នៅសាលាវិទ្យាល័យ និងសាកលវិទ្យាល័យ។

*ថៃ បញ្ញា*

## PhsarTauch Community Delivers aid to Poor Family during Pchum Ben

50 families received aid organized and distributed by the PhsarTauch church on the occasion of Pchum Ben.

Mr. Thai Panha, a charity committee leader, said the church has been organizing two programs a year for poor families. "We first organized during Khmer New Year and then a second time during Pchum Ben," said Mr. Panha. He added that the aid came from the  people and other donors. "The number of families we can help is determined by the amount of giftsgiven by Christians and donors. When we have more sponsors, we can find more families," said Mr. Panha. Each family received rice, sauce, and sugar The church also has a program to provide scholarships to students who study in high school or university.



# ព្រះសហគមន៍បឹងទំពន់ ស្វាគមន៍លោកអភិបាលដឹកនាំសំណាក់ធម៌សម្រាប់រដូវរង់ចាំ





គ្រីស្តបរិស័ទជាច្រើននាក់បានចូលរួមសំណាក់ធម៌ដែលដឹកនាំដោយលោកអភិបាលអូលីវីយេកាលពីថ្ងៃទី៤ ខែវិច្ឆិកា កន្លងទៅនេះ។

លោកអភិបាលអូលីវីយេ មានប្រសាសន៍ថា ព្រះសហគមន៍មានតិចតួចនៅក្នុងប្រទេសកម្ពុជា តែគ្រីស្តបរិស័ទ មានសេចក្តីស្រលាញ់ ក្នុងមិត្តភាពរវាងគ្នានឹងគ្នាយ៉ាងជិតស្និតដែលអាចបង្ហាញ សេចក្តីស្រលាញ់ និងធម៌មេត្តាករុណាដល់អ្នកដទៃបាន។

លោក ថុង ថន ជាគ្រូអប់រំជំនឿនៃព្រះសហគមន៍បឹងទំពន់មានប្រសាសន៍ថា លោកមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការជួយណែនាំរបស់លោកអភិបាល។ លោកបន្តថា យើងជាគ្រីស្តបរិស័ទ យើងត្រូវតែភ្ជាប់ខ្លួនយើងយ៉ាងជិតស្និទ្ធទៅនឹងព្រះសហគមន៍។ ព្រះសហគមន៍គឺជាសេចក្តីស្រលាញ់ ពោលគឺព្រះសហគមន៍ស្វាគមន៍មនុស្សទាំងអស់ឲ្យទៅជាមហាគ្រួសារតែមួយដោយមានព្រះជាម្ចាស់ជាអ្នកណែនាំយើង។

នៅក្នុងរដូវរង់ចាំនេះ លោកអភិបាលអូលីវីយេ នឹងធ្វើដំណើរតាមមណ្ឌលសកម្មភាពទាំង៧ នៅក្នុងភូមិភាគភ្នំពេញក្នុងគោលបំណងដើម្បីសួរសុខទុក្ខនិងដឹកនាំសំណាក់ធម៌សម្រាប់ រដូវរង់ចាំ។ វាជាឱកាសមួយសំខាន់ណាស់ដើម្បីឲ្យគ្រីស្តបរិស័ទស្គាល់ព្រះយេស៊ូយ៉ាងច្បាស់ ក្នុងពេលដែលកំពុងរង់ចាំព្រះអង្គ។

## Boeung Tumpun Church welcomes Bishop for Recollection During Advent

Many people in Boeung Tumpun warmly welcomed Bishop Olivier who led a recollection for the Advent season on November 4.

The aim of the recollection is to help every Christian know the church and our faith clearly. Bishop Olivier said that the church can be described as a sacrament of Jesus Christ. “She [the church] was created by Jesus. Therefore she can lead her people to meet God,” said Bishop Olivier.

Mr. Thong Than, a catechist at Boeung Tumpun, said he was very impressed by the talk of the bishop. He added that we should be close to the church because she is a sign of love and welcomes all kinds of persons into her family.

During Advent, Bishop Olivier plans to visit and lead recollections forall the seven pastoral centers. This is an important journey to help each place have a better understanding of Jesus and the church.

# មហាសន្និបាតតំណាងលោកអភិបាលនៅ បូរីវ៉ាទីកង់ ប្រទេសអ៊ីតាលី



















# កាលី កាលពីខែតុលា ឆ្នាំ២០១២ កន្លងមក



















# ព្រះសហគមន៍ប្រារព្ធពិធីបើកឆ្នាំនៃជំនឿ

គ្រីស្តបរិស័ទប្រមាណជាច្រើននាក់ បានចូលរួមក្នុងកម្មវិធីបើកឆ្នាំនៃជំនឿ នៅព្រះវិហារសន្ត យ៉ូសែបផ្សារតូច នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ កាលពីព្រឹកថ្ងៃទី៩ ខែវិច្ឆិកាកន្លងទៅនេះ។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ឲ្យដឹងថា ជារៀងរាល់ឆ្នាំក្នុងពិភពលោកទាំងមូលសម្តេចប៉ាបយ៉ូហាន ទី២៣បានសុំឲ្យព្រះសហគមន៍មានឆ្នាំនៃជំនឿដើម្បីជួយឲ្យគ្រីស្តបរិស័ទភ្ញាក់ស្មារតីម្តងទៀតអំពីជំនឿផ្ទាល់ខ្លួន និងម្យ៉ាងវិញទៀតគឺដើម្បីឲ្យព្រះសហគមន៍ ចេះរបៀបនៃការប្រកាសដំណឹងល្អទៅមនុស្សគ្រប់គ្នាលើពិភពលោកទាំងមូល។ លោកបានបន្តថា ក្នុងឆ្នាំនៃជំនឿនេះដែរ ព្រះសហគមន៍ ជាពិសេសភូមិភាគភ្នំពេញនឹងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅការអានព្រះគម្ពីរតាមសន្ត លូកា។

អ្នកស្រី ជុំ ចន្ទី ដែលមកពីព្រះសហគមន៍កាតូលិកយ៉ូសែប សែនសុខ១ បានប្រាប់ឲ្យដឹងថា "ព្រះសហគមន៍បានដាស់តឿនយើងគ្រប់ពេលវេលាដើម្បីឲ្យភ្ញាក់ស្មារតី និងត្រៀមខ្លួនជានិច្ចដើម្បីនៅជិតព្រះជាម្ចាស់។ ខ្ញុំមានចិត្តរំភើបជាខ្លាំងដែលយើងមានឱកាសជួបជុំគ្នាដើម្បីឲ្យយើងមានចិត្តថ្លើមតែមួយ"។

## The Cambodian Church Celebrate the Opening of the Year of Faith

Hundreds of people joined the opening of the Year of Faith at St. Joseph PhsarTauch on November 9, presided over by Bishop Olivier, bishop of Phnom Penh Vicariate, and Bishop Antony, bishop of Kampong Cham Prefecture.

Bishop Olivier said that since Pope John Paul XXIII, the church has created different kinds of Years to help Christians to reflect about their personal faith and growth in God's life. And the Year of Faith will help the church to find and develop new ways to evangelize the world. For this Year of Faith, we follow the gospel of St. Luke.

Mrs. ChomChany, from SenSok community, said the church always encourages us. "I am happy that we have this purpose for our church," said Mrs. Chany.









# សាលាអប់រំគ្រីស្តបរិស័ទសន្តចាស្ទីន ចាប់ផ្តើមបើកឆ្នាំសិក្សារបស់ខ្លួនហើយ





សាលាអប់រំគ្រីស្តបរិស័ទចាប់ផ្តើមកម្មវិធីសិក្សាឆ្នាំទី២របស់ខ្លួនកាលពីថ្ងៃ២៨ខែកញ្ញាកន្លងទៅនេះ។

លោកផុន សុផលជានាយកសាលាបានមានប្រសាសន៍ថា ក្នុងឆ្នាំសិក្សាឆ្នាំទីពីរនេះ គឺតម្រូវឲ្យនិស្សិតសិក្សានូវមុខវិជ្ជាចំនួន ៦ គឺទេវវិទ្យា បង្រៀនដោយលោកអភិបាលអូលីវីយេ សីលធម៌បង្រៀនដោយលោកបូជាចារ្យ ប៊្រុយណូ ផ្លូវវិញ្ញាណបង្រៀនដោយលោកបូជាចារ្យ ម៉ារីយ៉ូ ព្រះគម្ពីរបង្រៀនដោយលោកបូជាចារ្យ វ៉ាំងសង់ ប្រវត្តិព្រះសហគមន៍បង្រៀនដោយលោកបូជាចារ្យ បប់ និងទស្សនវិទ្យាបង្រៀនដោយលោកបូជាចារ្យ អាស្លី អេវ៉ាន់។ លោកក៏បានឲ្យដឹងទៀតដែរថា នៅចុងឆ្នាំសិក្សា២០១២-២០១៣ នេះ សាលានឹងមានគម្រោងទៅធ្វើទស្សនៈកិច្ចព្រះសហគមន៍នៅប្រទេសអ៊ីស្រាអែល ដែលនេះគឺជាទស្សនកិច្ចជាលើកទីពីរក្នុងកម្មវិធីរបស់ខ្លួនប្រសិនបើគ្មានអ្វីកើតឡើងខុសប្រក្រតី។

លោកធឹម ស៊ីធី ជានិស្សិតម្នាក់មានប្រសាសន៍ថា សាលាអប់រំគ្រីស្តបរិស័ទនៃសន្តចាស្ទីន ជាផ្លូវមួយដ៏សំខាន់ក្នុងការអនុញ្ញាតឲ្យគ្រីស្តបរិស័ទអាចស្វែងយល់អំពីជំនឿ និងសង្គមបានយ៉ាងជ្រៅ។ លោកពោលថា ជាការពិតណាស់ ជំនឿរបស់យើងអាចចាក់ឫសយ៉ាងជ្រៅបានដោយអាស្រ័យទៅលើការយល់ដឹងយ៉ាងទំលំទូលាយអំពីវា។ លោកអះអាងថាលោកទទួលបានបទពិសោធន៍យ៉ាងទូលំទូលាយតាមរយៈដំណើរទស្សនកិច្ចសិក្សានៅប្រទេសវៀតណាមដែលដំណើរនេះបានធ្វើឲ្យលោក ភ្ញាក់ស្មារតី និងឃើញពីរបៀបដែលគ្រីស្តបរិស័ទត្រូវអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន។

## St. Justin School of Faith Opens the second year

The first group of students at the St. Justin School of Faith has successfully finished the first year of studies in which they took an historic study tour in three neighboring countries.

Mr. PhonSophal, the executive director, said that students in the second year need to study 6 subjects: Theology, Ethics, Spirituality, Bible, Church history, and Philosophy. He added that at the end of the academic year, the school is planning to have a study tour to Jerusalem, Israel.

Mr. ThimSitim, a student who now works with CCCC, said St. Justin is a way which allowedhim to understand his faith more deeply. "I am sure that faith certainly relates to the understanding of what we believe," said Mr. Sithim. He added that school has given him a great chance to see the world especially through the study tour that he took in Vietnam. "We experience and understand what they are doing there, especially the way they relate their life with the church," Mr. Sithim said.

After the first group of students is finished, the school is going to welcome new students for the second group.

# របាយការណ៍ប្រចាំ ៣ខែកន្លងមក របស់ការិយាល័យយុវជន-កុមារ





ប្រជុំលើកទី២ សំរាប់រៀបចំ សន្និបាតយុវជន ភូមិភាគភ្នំពេញ ក្រោមប្រធានបទ "ចូរចាក់ឫស និង កសាង ជីវិតលើព្រះយេស៊ូគ្រីស្ត, ចូររក្សាជំនឿឲ្យបានរឹងប៉ឹង"។ ការប្រជុំនេះបានប្រព្រឹត្តឡើងនៅព្រះវិហារបឹងទំពុន នាថ្ងៃទី ២១-២២ ខែកក្កដា ឆ្នាំ២០១២ ដោយមានការចូលរួមពីប្រធាន-អនុប្រធាន យុវជនប្រចាំភូមិភាគភ្នំពេញទាំងមូល សរុប ៥៦ នាក់។

នាថ្ងៃទី ២៥-២៦ ខែ សីហា ឆ្នាំ២០១២ ការិយាល័យយុវជនភូមិភាគភ្នំពេញបាន ចុះធ្វើសិក្ខាសាលា លើកទី៣ក្រោមប្រធានបទ "ព្រះយេស៊ូរងទុក្ខលំបាក សោយទីវង្គត និង មានព្រះជន្មរស់ឡើងវិញ"។ សិក្ខាសាលាលើកទី៣នេះបានដំណើរការយ៉ាងរលូនដោយមាន យុវជនយុវនារី ចំនួន ៤៦នាក់ ចូលរួមយ៉ាងច្រើនកុះករ នៅក្នុងព្រះសហគមន៍ព្រះវិហារសន្តមីកាអែល នៅខេត្តព្រះសីហនុ។

នាថ្ងៃទី ១៣-១៦ ខែកញ្ញា ឆ្នាំ២០១២ ការិយាល័យយុវជន-កុមារភូមិភាគភ្នំពេញ បានរៀបចំកម្មវិធីបោះជុំរុំនិងពង្រឹងសម្ថតិភាពអ្នកណែនាំក្រុមកុមារកាយឫទ្ធិ នៅក្នុងភូមិភាគភ្នំពេញទាំងមូល។ នៅក្នុងនោះមានការចូលរួមពីសំណាក់ពីអ្នកណែនាំក្រុមកាយឫទ្ធិ ទាំង៧ មណ្ឌលសកម្មភាព នៅក្នុងភូមិភាគភ្នំពេញ ដែលមានចំនួនសរុប ១៧០នាក់ ក្រោមប្រធានបទ "ទំនាក់ទំនងរបស់ខ្ញុំ"។ កម្មវិធីនេះត្រូវអនុវត្តដោយការិយាល័យយុវជន-កុមារ ដោយមានការជ្រំជ្រែងទាំងកំលាំងកាយ កំលាំងចិត្តពីលោក ឪពុក,បងប្រុស, បងស្រី និងគណៈកម្មការតាមព្រះសហគមន៍នីមួយៗ ជាពិសេសជាងនេះទៀតគឺការគាំទ្រពីសំណាក់លោកអភិបាល អូលីវីយេ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ។ លោកបានឧបត្ថម្ភទាំងសម្ភារៈ និងគំនិត ដែលធ្វើឲ្យកម្មវិធីនេះបានទទួលផលផ្លែ ជាទីមោទនៈ ។




នាថ្ងៃទី៣-៧ ខែកញ្ញា ឆ្នាំ២០១២ ព្រឹត្តិការណ៍ប្រចាំឆ្នាំ បានប្រព្រឹត្តឡើងនៅសាលាបច្ចេកទេសដុនបូស្កូ គឺការប្រជុំសន្និបាតយុវជនប្រចាំភូមិភាគភ្នំពេញ ក្រោមប្រធានបទ "ចូរចាក់ឫស និង កសាងជីវិតលើព្រះយេស៊ូគ្រីស្ត, ចូររក្សាជំនឿឲ្យបានរឹងប៉ឹង"។ ក្នុងនោះដែរក៏មានការចូលរួម ជាអធិបតីពីសំណាក់លោកអភិបាលអូលីវីយេ ជាអភិបាលភូមិភាគភ្នំពេញផង។

ក្នុងអង្គសន្និបាតនេះមានការចូលរួមពីយុវជនចំនួន ៣៨៥នាក់ ក្នុងភូមិភាគភ្នំពេញទាំងមូលផងដែរ។














នៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១២ ការិយាល័យយុវជន និង កុមារភូមិភាគភ្នំពេញ បានរៀបចំការប្រជុំប្រធាន-អនុប្រធានយុវជន ចំនួន ១៦នាក់ ដែលគ្រប់មណ្ឌលសកម្មភាព។ ការចូលរួមនេះក្នុងគោលបំណង ដើម្បីរៀបចំបូជនីយចរសំរាប់ភូមិភាគភ្នំពេញនាថ្ងៃទី ១៦-១៨ ខែវិច្ឆិកា ឆ្នាំ២០១២ខាងមុខនេះ ព្រមទាំងផ្តល់ពត៌មាន,ចំនួនយុវជនដែលចូលរួម និង មតិយោបល់ផ្សេងៗក្នុងគោលបំណងឲ្យកម្មវិធីនេះប្រព្រឹត្តទៅដោយរលូន។ គួរបញ្ជាក់ថាកម្មវិធីបូជនីយចរនេះនឹងប្រព្រឹត្តនៅ ព្រះសហគមន៍ ក្តុលលើ ក្នុងស្រុកក្រូចឆ្មា ខេត្តកំពង់ចាម។ ចំងាយដែលយុវជនយុវនារីត្រូវដើរក្នុងបូជនីចរនេះគឺប្រមាណ ២០គីឡូម៉ែត្រ។

# សម្រង់សេចក្តីអធិប្បាយព្រះបន្ទូល របស់លោកអភិបាលអូលីវីយេ ឝ្មិតអឺស្លែរ ថ្ងៃទី ០៩/១១/២០១២

១. សូមថ្លែងព្រះគម្ពីរដំណឹងល្អតែងដោយសន្តលូកា

លោកអភិបាល លោកឪពុកបងប្អូនជាទីស្រឡាញ់ ថ្ងៃនេះយើងជួបជុំគ្នាជាព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ រួមជាមួយតំណាងមកពីភូមិភាគកំពង់ចាម។ ជាឱកាសមួយ ដែលអនុញ្ញាតិឲ្យយើងជួបជុំគ្នាដើម្បីបើកឆ្នាំនៃជំនឿ ដែលសម្តេចប៉ាបបានអញ្ជើញយើងឲ្យ មានឆ្នាំនៃជំនឿឆ្នាំនេះ។ ឆ្នាំនេះ សម្តេចប៉ាបបេនិកតូទី១៦ អញ្ជើញយើងយើងឲ្យគិតពិចារណាអំពីជំនឿរបស់យើង ជាឱកាសមួយដើម្បីបន្តនៅក្នុងព្រះសហគមន៍ម្តងទៀត អំពីជំនឿរបស់យើងលើព្រះជាម្ចាស់ ដែលជាព្រះបិតាព្រះបុត្រានិងព្រះវិញ្ញាណដ៏វិសុទ្ធ។ សម្រាប់ការរិះគិតរបស់យើងថ្ងៃនេះ ខ្ញុំមានសំនួរពីរ សំនួរទីមួយគឺ បេសកកម្មរបស់ព្រះសហគមន៍គឺជាអ្វី?។ សំនួរទីពីរគឺ ព្រះសហគមន៍ដែលព្រះយេស៊ូបានបង្កើតពេលណា? ចំពោះសំនួរទីមួយដែលបានសួរថា តើបេសកកម្មរបស់ព្រះសហគមន៍ជាអ្វីនោះ យើងបានស្តាប់នៅអត្ថបទគម្ពីរដំណឹងល្អ ពេលព្រះយេស៊ូបានចូលនៅក្នុងធម្មសាលា ព្រះអង្គបានបើកនឹងបានអានគម្ពីរដូចនេះ "ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ បានសណ្ឋិតលើខ្ញុំ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំឲ្យនាំ ដំណឹងល្អទៅប្រាប់ជនក្រីក្រ"។ នេះជាបេសកកម្មរបស់ព្រះសហគមន៍ ជាអ្វីដែលព្រះយេស៊ូបានចាប់ផ្តើមប្រកាសដំណឹងល្អដល់ជនក្រីក្រ។ កុំឲ្យយើងយល់ច្រឡំអំពីជនក្រីក្រ កុំឲ្យយើងគិតតែអ្នកដែលខ្វះខាត ដែលគ្មានទីពឹងពិតមែន ប៉ុន្តែដល់មនុស្សដែលគ្មានទីពឹងនៅក្នុងជីវិតរបស់គេខាងវិញ្ញាណ ដល់មនុស្សដែលគ្មានសេចក្តីសង្ឃឹមនៅក្នុងជីវិត ដោយសារផ្ញើសេចក្តីសង្ឃឹមរបស់គេទាំងអស់លើសំភារៈ លើសង្គមដែលយើងរស់នៅ។ ដូច្នេះហើយ នៅពេលព្រះយេស៊ូប្រកាសដំណឹងល្អ ដល់អ្នកក្រីក្រគឺមានន័យថា ព្រះអង្គប្រកាសដល់អ្នកទាំងឡាយណាដែលគ្មានព្រះជាម្ចាស់ ដែលគ្មានព្រះយេស៊ូដែលជាដំណឹងល្អ ដែលគ្មានសេចក្តីសង្ឃឹមនៅក្នុងជីវិត។ ពេលព្រះយេស៊ូចាប់ផ្តើម បេសកកម្មរបស់ព្រះអង្គដោយពាក្យមួយដ៏សំខាន់ ព្រះវិញ្ញាណរបស់ព្រះ អម្ចាស់សណ្ឋិតលើខ្ញុំ។ មានន័យថា ពីដើមរៀងមកនៅពេលព្រះយេស៊ូចាប់ផ្តើមប្រកាសដំណឹងល្អ ព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើព្រះអង្គ។ ចាប់តាំងពីថ្ងៃដំបូងរហូតដល់សព្វថ្ងៃប្រហែល២០០០ឆ្នាំហើយ មានន័យថា ព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើព្រះសហគមន៍ គ្រប់សកម្មភាពគ្រប់ការងារដែលយើងធ្វើ យើងអាចជោគជ័យ នៅពេលដែលយើងធ្វើក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ខ្ញុំបាននិយាយអំពីសម្តេចប៉ាបយ៉ូហានទី២៣ ដែលបានបង្កើតមហាសន្និបាតវ៉ាទីកង់ទីពីរ នៅពេលនោះគាត់បានចាប់ផ្តើមសកម្មភាពនេះនៅក្នុងកំលាំងដែលគាត់ទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយសារគាត់ចាស់ហើយ គាត់គ្មានកំលាំងដើម្បីប្រមូលលោកអភិបាល ២៥០០អង្គ ដើម្បីប្រជុំយូរខែយូរឆ្នាំ តែកំលាំងគាត់នៅមានដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។ ខ្ញុំដែលបានអង្គុយនៅមុខសម្តេចប៉ាប ជិត៣អាទិត្យ ខ្ញុំបានឃើញសម្តេចបាបចាស់ហើយ ពុំសូវមានកំលាំងកាយ ប៉ុន្តែកំលាំងចិត្តនៅមាន ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយ។ ព្រះវិញ្ញាណដ៏វិសុទ្ធគង់សណ្ឋិតលើព្រះយេស៊ូ ពីដើមនឹងសណ្ឋិតនៅលើព្រះសហគមន៍រហូតដល់សព្វថ្ងៃ។ ហេតុនេះហើយ ជាប់២០០០ឆ្នាំកន្លងមកព្រះសហគមន៍ខិតខំបំពេញបេសកកម្មរបស់ខ្លួន ដោយទទួលការណែនាំព្រះពន្លឺពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ប្រសិនបើយើងចង់និយាយ អំពីបេសកកម្មរបស់ព្រះសហគមន៍ណែនាំឲ្យបងប្អូននិងមនុស្សទាំងឡាយជួបជាមួយព្រះយេស៊ូផ្ទាល់។ ហេតុនេះហើយ ព្រះសហគមន៍ទៅជាអគ្គសញ្ញានៃព្រះគ្រីស្តតែពាក្យ អគ្គសញ្ញាទីនេះមិនមែនអគ្គសញ្ញាទាំង៧ដែលយើងស្គាល់ទេ ប៉ុន្តែព្រះសហគមន៍ជាអគ្គសញ្ញារបស់ព្រះគ្រីស្តដែរ។ នេះជាបេសកកម្មរបស់ព្រះសហគមន៍ គឺបង្ហាញសញ្ញាដ៏វិសេសបំផុត សម្រាប់បង្ហាញអំពីព្រះយេស៊ូ។ បេសកកម្មព្រះសហគមន៍គឺបង្ហាញព្រះយេស៊ូ ណែនាំឲ្យអ្នកដទៃស្គាល់ព្រះយេស៊ូ។

តើយើងធ្វើដូចម្តេចដើម្បីបង្ហាញព្រះគ្រីស្ត ដើម្បីណែនាំឲ្យអ្នកដទៃស្គាល់ព្រះយេស៊ូ។ ឲ្យយើងនឹកឃើញដល់អត្ថបទមួយទៀតគឺព្រះយេស៊ូកំពុងអង្គុយនៅមាត់អណ្តូងទឹក ដែលមានស្ត្រីសាសន៍

សាម៉ារីម្នាក់មកដងទឹកពេលនោះព្រះយេស៊ូចាប់ផ្តើមនិយាយជាមួយគាត់ ព្រះអង្គដឹងទាំងអស់ពីស្រ្តីនោះ ធ្វើឲ្យស្រ្តីនោះឆ្ងល់ថាហេតុអីព្រះយេស៊ូស្គាល់ខ្ញុំម្ល៉េះ?។ បន្តិចម្តងៗព្រះយេស៊ូណែនាំនាងហើយមិនមែនព្រះយេស៊ូដែលសុំទឹកពីគាត់ប៉ុន្តែជាស្រ្តីសាសន៍សាម៉ារីនោះដែលសុំទឹកពីព្រះយេស៊ូវិញ តែមិនមែនទឹកដែលចេញពីអណ្តូងទឹក គឺទឹកដែលផ្តល់ជីវិតអស់កល្បជានិច្ច។ ខ្ញុំមានចំនុចខ្លះៗ ចំនុចទីមួយ ការជួបជុំគ្នាដើម្បីបង្កើតទំនាក់ទំនង។ ដើម្បីប្រកាសដំណឹង ល្អចំនុចទីមួយ គឺសុខចិត្តជួប ជុំគ្នាជួបអ្នកដទៃ និយាយជាមួយគេសួរសុខទុក្ខគេ។ វាជាដំណាក់កាលទីបីនៅក្នុងការប្រកាសដំណឹងល្អ ទីមួយបង្កើតទំនាក់ទំនង ទីពីរធ្វើការសន្ទនានិយាយគ្នា ទីបីយល់ ចិត្តគ្នា។ ទីបួនកុំឲ្យយើងវិនិច្ឆ័យ កុំឲ្យយើងកាត់ក្តី ដោយគិតថាយើងមានសេចក្តីពិត យើងជាមនុស្សត្រឹមត្រូវ នឹងអ្នកដទៃជាមនុស្សអាក្រក់។ ព្រះយេស៊ូដែលបានជួប ជាមួយស្រ្តីសាសន៍សាម៉ារីមិនវិនិច្ឆ័យគាត់ទេ ទោះបីគាត់មានប្តីយ៉ាងច្រើន។ ផ្ទុយទៅវិញព្រះយេស៊ូជួយគាត់ឲ្យគាត់បើកភ្នែកមើលជីវិតរបស់គាត់ ផ្ទាល់ខ្លួនដើម្បីឲ្យគាត់កែប្រែចិត្តគំនិត។ នេះជាចំនុចទីបួន កុំឲ្យយើងវិនិច្ឆ័យកុំឲ្យយើងកាត់ក្តី ប៉ុន្តែឲ្យយើងជួយបងប្អូនឯទៀតៗ ឲ្យបើកភ្នែកមើលជីវិតផ្ទាល់ខ្លួន ដើម្បីទទួលព្រះពន្លឺសេចក្តីស្រលាញ់របស់ព្រះយេស៊ូ។ ស្រ្តីសាសន៍សាម៉ារីនេះ ពេលគាត់យល់អំពី សេចក្តីស្រលាញ់របស់ព្រះយេស៊ូ គាត់លែងភ័យលែងខ្លាចគាត់ បើកភ្នែករបស់គាត់ នឹងគាត់អាច កែប្រែចិត្តគំនិតបាន។ តែមិនមែនគាត់កែប្រែចិត្តគំនិត ក្នុងអត្ថន័យគាត់ភ័យគាត់ខ្លាច ប៉ុន្តែដោយសារគាត់យល់អំពីសេចក្តីស្រលាញ់ របស់ព្រះជាម្ចាស់ ចំនុចទីប្រាំ គឺព្រះយេស៊ូជាទឹក ដែលផ្តល់ជីវិតអស់កល្បជានិច្ច យើងទៅដល់ទិសដៅគឺព្រះយេស៊ូសោយទិវង្គតនឹងមាន ព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូជាជីវិតអស់កល្បជានិច្ចសម្រាប់យើងម្នាក់ៗ។ ចំនុចចុង ក្រោយក្នុងការប្រកាសដំណឹងល្អ អ្នកដែលបានកែប្រែចិត្តគំនិត ដែលបានទទួលព្រះបន្ទូលថ្មីគឺអ្នកនោះដែលទៅនិយាយតៗ ដើម្បីផ្តល់សក្ខីភាពណែនាំអ្នកដទៃ ទទួលព្រះបន្ទូលដំណឹងល្អ គឺព្រះយេស៊ូជាជីវិតអស់កល្បជានិច្ច។ ស្រ្តីសាសន៍សាម៉ារីនៅពេលគាត់ភ្ញាក់ស្មារតី នៅពេលគាត់ទទួលជីវិតអស់កល្បជានិច្ច គាត់បានរត់ទៅប្រាប់គេ ខ្ញុំបានជួបលោកដែលស្គាល់ខ្ញុំហើយ។ នេះណែនាំឲ្យអ្នកផ្សេងក៏គេចង់ ស្គាល់ព្រះយេស៊ូដែរ។ ហេតុនេះហើយសរុបសេចក្តី អំពីរបៀបដែលយើងត្រូវតែប្រកាសដំណឹងល្អតាមរយៈសេចក្តីស្រលាញ់។ សម្រាប់យើង ដែលនៅប្រទេសកម្ពុជាក្នុងអត្ថបទទីពីរ យើងបានស្តាប់ចំនុច ខ្លះដែលណែនាំឲ្យយើងយល់យ៉ាងច្បាស់ យើងធ្វើដូចម្តេចដើម្បីអនុវត្តអ្វីៗទាំងអស់ដែលខ្ញុំបាននិយាយអំបាញ់មិញ។ អត្ថបទ "លើសពីនេះទៅទៀតត្រូវមានចិត្តស្រលាញ់ត្បិតសេចក្តីស្រលាញ់ធ្វើឲ្យបងប្អូនរួបរួមគ្នាពេញលក្ខណៈ"។នេះជាមូលដ្ឋានគ្រឹះដើម្បីធ្វើជាសាក្សីថ្លែងព្រះបន្ទូលដំណឹងល្អដូចព្រះយេស៊ូនៅក្នុងរបៀបព្រះយេស៊ូ ឲ្យយើងមានចិត្តស្រលាញ់។ នេះជាសំនួរដែលយើងត្រូវតែគិតពេញមួយឆ្នាំនេះ តើព្រះសហគមន៍ដែលព្រះយេស៊ូ បានបង្កើត ពេលណា?។ ។ ព្រះសហគមន៍ចេញ ពីនេះ ពេលព្រះយេស៊ូលុត ជង្គង់នៅមុនក្រុមគ្រីស្តទូត ពេលកំពុងលាងជើងក្រុមគ្រីស្តទូត គឺនៅពេលនោះដែលព្រះសហគមន៍ចាប់ផ្តើមចេញមក។ នៅពេលក្រុមគ្រីស្តទូតបានជួបជុំគ្នា មុនចាប់ផ្តើមចាក់ចេញដើម្បីប្រកាសដំណឹងល្អនេះព្រះសហគមន៍បានកើតឡើង។ ហេតុនេះហើយពីថ្ងៃដែលព្រះយេស៊ូលាងជើង ព្រះយេស៊ូសោយទិវង្គត ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូចាត់ព្រះវិញ្ញាណដ៏វិសុទ្ធវាជាពេលវេលា ទាំងអស់ដែលព្រះសហគមន៍បានកើតឡើង។ ហេតុនេះហើយព្រះសហគមន៍យើង ជាព្រះសហគមន៍ដែលបម្រើបងប្អូនឯទៀតៗ ព្រះសហគមន៍យើងដែលរស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ព្រះសហគមន៍យើង ជាព្រះសហគមន៍ដែលចេញដើម្បីទៅប្រកាសដំណឹងល្អ ព្រះសហគមន៍យើងជាក្រុមគ្រួសារដែលចេះរួបរួមគ្នា ជាធ្លុងតែមួយនៅក្នុងអង្គព្រះគ្រីស្តនឹងក្រុមគ្រីស្តទូតពីដើម។ នេះជាព្រះសហគមន៍ដែលព្រះយេស៊ូបានបង្កើត។ ឆ្នាំនេះឲ្យយើងគិតពិចារណាអំពីព្រះសហគមន៍ដែលព្រះវិញ្ញាណព្រះយេស៊ូបានបង្កើត និងអំពីព្រះសហគមន៍យើង។ តើយើងធ្វើដូចម្តេច ដើម្បីឲ្យព្រះសហគមន៍យើងក្នុងប្រទេសកម្ពុជា ទៅជាព្រះសហគមន៍ដែលព្រះយេស៊ូបានបង្កើត?។ នេះជាសំនួរដែល ខ្ញុំទុកឲ្យបងប្អូនទាំងអស់សម្រាប់ឆ្នាំនៃជំនឿនេះ គឺឲ្យយើងគិតពិចារណា តើយើងធ្វើដូចម្តេច ដើម្បីឲ្យព្រះសហគមន៍យើងក្នុងប្រទេសកម្ពុជា ទៅជាព្រះសហគមន៍របស់ព្រះយេស៊ូគ្រីស្ត គឺព្រះសហគមន៍ដែលបម្រើ គឺព្រះសហគមន៍ដែលរស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះសហគមន៍ដែលជាធ្លុងតែមួយ នៅក្នុងព្រះយេស៊ូជាអម្ចាស់។ អាម៉ែន។

# មណ្ឌលសកម្មភាពទន្លេបាសាក់បង្កើតក្រុមតេរេសានៃព្រះកុមារយេស៊ូ



ព្រះសហគមន៍ទូទាំងមណ្ឌលសកម្មភាពទន្លេបាសាក់បានបង្កើតក្រុមតេរេសានៃព្រះកុមារយេស៊ូ។ តាមប្រសាសន៍របស់លោក បូជាចារ្យ វ៉ាន់ទីន ដែលជាអ្នកទទួលខុសត្រូវក្រុមនេះបានឲ្យដឹងថា មានកុមារប្រមាណជាជាង១៥០នាក់បានចូលរួមក្នុងក្រុមនេះ។ លោកបន្តថាគោលដៅនៃការបង្កើតក្រុមនេះឡើងគឺដើម្បីឲ្យកុមារទាំងនោះ ចេះអធិដ្ឋាន យល់ដឹងពីរបៀបអានព្រះគម្ពីរ ចេះបម្រើអាសនៈ ធ្វើជាកូនល្អក្នុងគ្រួសារ ទទួលអប់រំជំនឿ មានទម្លាប់និងសុជីវធម៌ល្អពេលចូលព្រះវិហារ មានការទទួលខុសត្រូវខ្ពស់លើការងារក្រុម ចែករំលែកការងារមួយចំនួនក្នុងព្រះសហគមន៍។

ក្រុមតេរេសាបានយកសន្តីតេរេសានៃព្រះកុមារយេស៊ូជាឧបការីនីសម្រាប់ណែនាំ។ ពួកគេជឿជាក់ថា ដោយធ្វើតាមគំរូរបស់សន្តីតេរេសាដែលសន្តីតែងតែស្តាប់បង្គាប់ព្រះយេស៊ូ ធ្វើឲ្យពួកគេយល់ពីសេចក្តីស្រលាញ់ ការលើកលែងទោស និងធ្វើជីវិតទាំងស្រុងលើព្រះអង្គដែរ។

ក្រុមនេះត្រូវបានបង្កើតឡើងក្រោយពេលលោកអភិបាល អូលីវីយេ សួរសុខទុក្ខ និងថ្វាយអភិបូជានៅព្រះសហគមន៍បឹងឈូកកាលពីខែមិថុនាកន្លងទៅ។ ក្នុងចំណោមកុមារជាង១៥០នាក់ មាន ៤០នាក់មកពីព្រះសហគមន៍ជ្រៃធំ ២០នាក់នៅព្រះសហគមន៍កោះទាវ ២០នាក់នៅព្រះសហគមន៍សំប៉ាន ២២នាក់នៅព្រះសហគមន៍ស្អាង ២៥នាក់ព្រះសហគមន៍ទួលក្រសាំង និង២៥នាក់មកពីព្រះសហគមន៍បឹងឈូក។

***Nyroth***

## St. Teresa of Jesus group at TonleBassac

The St. Teresa of Jesus group has been formed by groups of small children in every community of the TonleBassac pastoral center after a visit and encouragement from Bishop Olivier.

Fr. Levan Tin, the priest in charge of the TonleBassac pastoral center, based at Chrey Thom community, said there are about 150 children who come together and formed a group called "Teresa of Jesus". " This group is purposely created to teach those children to how to pray, read the bible, be a good child in the family, attend catechism classes, help with light work in the church, and grow up with a strong sense of self responsibility," said Fr. Tin.

Among those 150 children, there are 40 from Chrey Thom community, 20 from KohTiev, 20 from Sampan, 22 from Saang, 24 from ToulKrasang, 25 from Boeung Chhouk.



## *សកម្មភាពលោក សុខកុមារ អូលីវីយេ ជ្មីតអឺស្ស៊ែរ អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ក្នុងខែវិច្ឆិកា ឆ្នាំ២០១២*

ថ្ងៃទី៨ ខែវិច្ឆិកា ៖ពិធីបើកបវេសនកាល និងសម្ពោធកីឡដ្ឋានរបស់វិទ្យាស្ថាន ក្រោមអធិបតីភាពរបស់ ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃទី៩ ខែវិច្ឆិកា ៖ពិធីបុណ្យបើក "ឆ្នាំនៃជំនឿ"។

ថ្ងៃទី១០-១១ ខែវិច្ឆិកា ៖ណែនាំសំណាក់ធម៌នៅព្រះសហគមន៍តំបន់តាកែវ ។

ថ្ងៃទី១៤ ខែវិច្ឆិកា ៖អភិបូជា និង សួរសុខទុក្ខក្រុមសន្តមីកាអែល។

ថ្ងៃទី១៥ ខែវិច្ឆិកា ៖ប្រជុំក្រុមប្រឹក្សាប្រតិបត្តិ។

ថ្ងៃទី១៦ -១៨ ខែវិច្ឆិកា ៖បូជនីចរ ជាមួយក្រុមយុវជន។

ថ្ងៃទី១៩ ខែវិច្ឆិកា ៖សំណាក់ធម៌ជាមួយសម្ពន្ធកាតូលិកដើម្បីមនុស្សធម៌ និងការអភិវឌ្ឍន៍។

ថ្ងៃទី២០ ខែវិច្ឆិកា ៖ប្រជុំរៀបចំ មហាសន្និបាត ឆ្នាំ២០១៣ ( ខួប៥០ ឆ្នាំ វ៉ាទីកង់ទី២ ), អភិបូជា និងធ្វើបាឋកថា នៅទេវវិទ្យាល័យកម្ពុជា។

ថ្ងៃទី២២ ខែវិច្ឆិកា ៖ ប្រជុំក្រុមប្រឹក្សាប្រតិបត្តិ។

ថ្ងៃទី២៣ ខែវិច្ឆិកា ៖ ប្រជុំក្រុមសាសនទូតក្រៅទីក្រុងប៉ារីស

ថ្ងៃទី២៤ ខែវិច្ឆិកា ៖ បង្រៀននៅសាលា សន្ត យ៉ាស្ទីន

ថ្ងៃទី២៤-២៥ ខែវិច្ឆិកា ៖សួរសុខទុក្ខ និងណែនាំសំណាក់ធម៌ នៅព្រះសហគមន៍តំបន់ទន្លេបាសាក់។

ថ្ងៃទី២៦-៣០ ខែវិច្ឆិកា ៖ប្រជុំក្រុមលោកអភិបាល ឡាវ-កម្ពុជា នៅប៉ាកសេ ប្រទេសឡាវ។

## The activities of Bishop Olivier Schmitthaeusler, MEP Apostolic Vicar of Phnom Penh, Novermber 2012

**November 8th** : Opening new academic year at St. Paul institute and inauguration of the sports ground with the present of H.E Em Sethy, ministry of education youth and Sports.

**November 9th** : Opening celebration of the Year of Faith

**November 10th – 11th** : Recollection at Takeo Sector

**November 14th** : Mass and Visit to Saint Michael

**November 15th** : Mission Council Meeting

**November 16th -18th** : Youth Pilgrimage

**November 19th** : Retreat with Catholic Alliance for Charity and Development, CACD

**November 20th** : The Meeting of the Preparation for the Congress 2013 (50th Vatican II)

: Mass and Conference at the Major Seminary

**November 22nd** : Mission Council Meeting

**November 23rd** : MEP meeting

**November 24th** : Teach at St. Justin School

**November 24th -25th** : Visit and Recollection at Bassac Sector

**November 26th – 30th** : Meeting of Bishop Conference – Laos and Cambodia at Pakse (Laos)

# រូបភាពប្រចាំខែ














**ព្រះសហគមន៍ភូមិភាគភ្នំពេញ**

**ព្រឹត្តិបត្រ ជីវិត**

អ្នកទទួលខុសត្រូវ: លោកអភិបាល  អូលីវីយេ ឆ្មិតអ៊ីស្លែរ

Tel: 023 212 462

Email: apostolicvicariate.phnompenh@gmail.com

ការីនិពន្ធ: ញឹប ញឿន

Email: markgnuen@gmail.com

ការិយាល័យផ្សព្វផ្សាយពត៌មានកាតូលិក

# ២៥ ផ្លូវ២៤២ បឹងព្រលឹត ៧មករា ភ្នំពេញ.

**Apostolic vicariate Phnom Penh**

**LIFE NEWSLETTER**

**Chairman:** Msgr. Olivier Schmitthaeusler.

**Tel:** 023 212 462

**Email:** apostolicvicariate.phnompenh@gmail.com

**Editor:** Gneb Gnuen

**Email:** markgnuen@gmail.com

**Catholic Social Communications**

#25, St 242, Boeung Prolit, 7 Makara, Phnom Penh.